# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :......៣៥៦......ក.ប/ស.ជ.ណ.ព.ក

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារបានជ្រាបថា ដើម្បីបញ្ចៀសបាននូវគ្រោះថ្នាក់ការងារ ព្រមទាំងបង្ការការកើតមានករណីដួលសន្លប់ជាយថាហេតុដែលបណ្តាលមកពីបរិយាកាសទាំងក្នុង និងក្រៅអគារផលិតកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ជាពិសេសរោងចក្រ សហគ្រាសវាយនភ័ណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងទាំងអស់ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវវិធានការដូចខាងក្រោម៖

១- ត្រូវត្រួតពិនិត្យ និងថែទាំជាប្រចាំ និងបើកឱ្យដំណើរការប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់នៅតាមអគារផលិតកម្មទាំងអស់ឱ្យបានយ៉ាងហោច ១ម៉ោងមុនពេលអនុញ្ញាតឱ្យកម្មករនិយោជិតចូលបម្រើការងារ ស្របតាមប្រកាសលេខ១២៥ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ

២- ត្រូវត្រួតពិនិត្យតាមដានបរិវេណនៅជុំវិញទាំងក្នុង និងក្រៅអគារសហគ្រាស គ្រឹះស្ថានជាប្រចាំជាពិសេសមុនពេលអនុញ្ញាតឱ្យកម្មករចូលធ្វើការ ដើម្បីទប់ស្កាត់ និងបង្ការឱ្យបានទាន់ពេលវេលាក្នុងករណីមានការសាយភាយក្លិនសារធាតុគីមី ថ្នាំសម្លាប់សត្វល្អិត ឬសារធាតុដ៏ទៃទៀតចូលក្នុងអគារផលិតកម្ម និងនៅពេលមានការប្រើប្រាស់សារធាតុទាំងនោះនៅក្បែរអគារសហគ្រាស គ្រឹះស្ថាន

៣- ត្រូវបើកបង្អួច ទ្វារ ទាំងអស់ ឬបន្ថែមកង្ហារបញ្ចេញខ្យល់ ឬបឺតខ្យល់ចេញ ក្នុងអគារផលិតកម្មនៅពេលមានអាកាសធាតុក្តៅ។ ការរៀបចំទុកដាក់សម្ភារៈ និងវត្ថុធាតុដើមត្រូវទុកដាក់ឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាពកុំឱ្យបាំងប្រភពខ្យល់ចេញចូល ផ្លូវចេញចូល និងទ្វារអាសន្ននៅក្នុងអគារផលិតកម្ម

៤- ត្រូវដាក់ឱ្យមានឧបករណ៍វាស់ស្ទង់កំដៅ (សីតុណ្ហមាត្រ) នៅកន្លែងធ្វើការ ដើម្បីងាយស្រួលក្នុងការតាមដានការវិវត្តនៃកំដៅនៅក្នុងសហគ្រាស គ្រឹះស្ថាន ស្របតាមប្រកាសលេខ១៤៧ ស.ក.ប.យ ស្តីពីបរិយាការណ៍កម្តៅក្នុងទីកន្លែងធ្វើការ

៥- ត្រូវត្រួតពិនិត្យ និងថែទាំជាប្រចាំនូវប្រព័ន្ធបង្ការអគ្គិភ័យ និងសម្ភារការពាររួម នៅក្នុងអគារផលិតកម្មសហគ្រាស គ្រឹះស្ថាន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយធានាថាប្រព័ន្ធ និងឧបករណ៍ទាំងនោះអាចដំណើរការបាននៅពេលមានអាសន្នកើតឡើង ព្រមទាំងអនុវត្តតាមការណែនាំរបស់ក្រុមអធិការកិច្ចការងារ

៦- ត្រូវរៀបចំឱ្យមានគិលានដ្ឋាន និងមធ្យោបាយសង្គ្រោះបន្ទាន់ប្រចាំសហគ្រាស គ្រឹះស្ថាន ស្របតាមប្រកាសរួមលេខ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងគោលការណ៍ណែនាំការរៀបចំគិលានដ្ឋានសហគ្រាស គ្រឹះស្ថាន ...



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

៧- ត្រូវផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិត ស្របតាមប្រកាសលេខ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ

៨- ត្រូវធ្វើការអប់រំបណ្តុះបណ្តាលកម្មករនិយោជិត អំពីរបៀបជម្លៀសខ្លួន និងសញ្ញាការសុវត្ថិភាពនៅតាមប៉ុស្តិ៍ការងារ ស្របតាមប្រកាសលេខ១៧៦ ស.ក.ប.យ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព

៩- ចំពោះសហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់សារធាតុងាយឆាបឆេះ ត្រូវរៀបចំឱ្យមានប្រព័ន្ធឆ្លើយតបគ្រាអាសន្ន និងរក្សាទុកដាក់សារធាតុទាំងនោះឱ្យដាច់ដោយឡែក និងដាច់ឆ្ងាយពីអគារផលិតកម្ម

១០- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ប្រព័ន្ធឡចំហាយ ត្រូវរៀបចំតំឡើងប្រព័ន្ធឡចំហាយទៅតាមបទដ្ឋានបច្ចេកទេស និងសុវត្ថិភាព ព្រមទាំងមានលិខិតអនុញ្ញាតពីក្រសួងស្ថាប័នជំនាញ

១១- អ្នកទទួលខុសត្រូវ និងអ្នកបញ្ជាឡចំហាយ ត្រូវទទួលការអប់រំបណ្តុះបណ្តាលអំពីការគ្រប់គ្រងឡចំហាយ ការប្រតិបត្តិការ និងការថែទាំជាមុន ស្របតាមប្រកាសលេខ១៧៦ ស.ក.ប.យ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចាត់វិធានការតឹងរឹងបំផុតទៅតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋាននានាដែលមានជាធរមានចំពោះម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសនឹងចំណុចដែលបានរៀបរាប់ក្នុងសេចក្តីជូនដំណឹងនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១៤ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**__កន្លែងទទួល៖__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានពេទ្យការងារ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ